ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ...
ស្រុក ...
ផ្នែបាលឃុំ ...

លេខ...../២២ ដ.ក

ដីកា
ស្តីពី
ការលើកទឹកចិត្តយុវជនចូលរួមក្នុងកិច្ចការសង្គម

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣
- យោងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- យោងអនុក្រឹត្យលេខ ២២ អនុក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាលស្តីពីការធ្វើវិមជ្ឈការ អំណាច តួនាទី និងភារៈកិច្ចទៅអោយក្រុមប្រឹក្សាឃុំ សង្កាត់ ។
- យោងកិច្ចប្រជុំកាលពីថ្ងៃ...ខែ...ឆ្នាំ...របស់ក្រុមប្រឹក្សាឃុំ... និងយោងតាមការពិភាក្សាសម្រេចលើដីកាស្តីពីការលើកទឹកចិត្តដល់យុវជនក្នុងការចូលរួមក្នុងកិច្ចការសង្គមក្នុងឃុំ... ។
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋបាលឃុំ... ដោយយល់ឃើញថា បញ្ហាកង្វះការចូលរួមរបស់យុវជនក្នុងកិច្ចការសង្គម ជាពិសេសការចូលរួមនៅក្នុងការធ្វើផែនការអភិវឌ្ឍន៍ឃុំអាចមិនឆ្លើយតបទៅនឹងតម្រូវការរបស់យុវជននៅក្នុងសហគមន៍នៃឃុំ... ។

ដោយមើលឃើញពីការប្រឈមរបស់យុវជនដែលពុំសូវមានឱកាសក្នុងការចូលរួមក្នុងកិច្ចការសង្គម និងដើម្បីលើកទឹកចិត្តដល់យុវជនឱ្យចូលយ៉ាងសកម្ម ក្រុមប្រឹក្សាឃុំ...

សម្រេច

ប្រការ១._ ដីកានេះមានគោលបំណង លើកកម្ពស់សិទ្ធិ និងការចូលរួមរបស់យុវជនក្នុងកិច្ចការសង្គម និងផ្តល់ឱកាសដល់យុវជនខ្មែរទាំងពីរភេទបានចូលរួមយ៉ាងសកម្មនៅក្នុងការផ្តល់យោបល់ និងលើកឡើងនូវកង្វល់នានាដែលពាក់ព័ន្ធទៅនឹងតម្រូវការរបស់យុវជនតាមគោលគំនិត និងក្តីស្រមៃរបស់ខ្លួន។

ប្រការ២._ ដីកានេះមានសុពលភាពអនុវត្តតែនៅក្នុងដែនដី នៃឃុំ... ។

ប្រការ៣._ រដ្ឋបាលឃុំផ្តល់ឱកាស និងលើកទឹកចិត្តឱ្យក្រុមយុវជនចូលរួមនៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ។

ប្រការ៤._ ឯកបាលឃុំផ្តល់ឱកាស និងលើកទឹកចិត្តឱ្យក្រុមយុវជនចូលរួមនៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធីនិយោគបីឆ្នាំរំកិលរបស់ឃុំ ឯកភ្នំតូច។

ប្រការ៥._ ឯកបាលឃុំនឹងស្វែងរកកិច្ចសហការទូលំទូលាយជាមួយអ្នកពាក់ព័ន្ធរួមទាំងអង្គការ ជាពិសេសយុវជន ដែលទទួលបានជោគជ័យក្នុងការចូលរួមក្នុងកិច្ចការសង្គមឱ្យចែករំលែកបទពិសោធន៍ និងផ្តល់ការបណ្តុះបណ្តាលដល់យុវជនពីសិទ្ធិមនុស្ស ប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងសារៈសំខាននៃការចូលរួមរបស់យុវជននៅក្នុងឃុំ ។

ប្រការ៦._ ឯកបាលឃុំនឹងរៀបចំឱ្យមានការដាក់បង្ហាញអំពីតារាងតម្លៃសេវារដ្ឋបាលឱ្យបានទូលំទូលាយនៅតាមភូមិ ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ដឹងពីតម្លៃសេវារដ្ឋបាលនៃការផ្តល់សេវារបស់ឃុំប្រកបដោយតម្លាភាព។

ប្រការ៧._ រដ្ឋបាលឃុំ នឹងចែករំលែកព័ត៌មានពាក់ព័ន្ធពីការចូលរួមរបស់យុវជនក្នុងកិច្ចការសង្គម និងឱកាសសម្រាប់ការចូលរួមរបស់យុវជនជាមួយក្រុមប្រឹក្សាឃុំ ដល់ប្រជាពលរដ្ឋក្នុងឃុំ ជាពិសេសយុវជន តាមរយៈការបិទផ្សាយនៅក្តារព័ត៌មាននៅតាមភូមិ និងនៅសាលាឃុំ និងទំព័រហ្វេសបុកផ្លូវការរបស់រដ្ឋបាលឃុំ។

ប្រការ៨._ រដ្ឋបាលឃុំ នឹងបង្កលក្ខណៈងាយស្រួលដល់បណ្តាញ/ក្រុមយុវជនបានជួបជុំពិភាក្សាគ្នា និងផ្សព្វផ្សាយអំពីសិទ្ធិមនុស្ស ប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងតួនាទីរបស់យុវជនក្នុងការចូលរួមក្នុងកិច្ចការសង្គមដល់ប្រជាពលរដ្ឋ ជាពិសេសយុវជននៅក្នុងសហគមន៍ឱ្យបានយល់ដឹងយ៉ាងទូលំទូលាយ។

ប្រការ៩._ ក្រុមប្រឹក្សាឃុំ ឯកភ្នំតូច នឹងជួយសម្រួលរាល់ឯកសារដែលទាក់ទងទៅនឹងតម្រូវការរបស់យុវជនជាមួយនឹងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។

ប្រការ១០._ ដីកានេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃអង្គារ៍ ទី១៤ ខែ កក្កដា ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ឯកភ្នំតូច ថ្ងៃទី២៧ ខែ តុលា ឆ្នាំ២០២២

មេឃុំ

ហួស ឫទ្ធ

ចំលងជូន
- រដ្ឋបាលស្រុក ឯកគរ
- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមស្រុក ឯកឃ
  -ដើម្បីគោរពជូនជ្រាប-
- មេភូមិគ្រប់ភូមិ
  -ដើម្បីសហការអនុវត្តន៍-
- ឯកសារ-តាលប្បវត្តិ